ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ...............................

# កំណត់ហេតុកិច្ចប្រជុំ
## រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែវិច្ឆិកា ថ្ងៃទីដប់ប្រាំបី វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាអន្តរក្រសួង រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ។

សមាសភាពចូលរួមកិច្ចប្រជុំសរុបចំនួន ៤៣រូប រួមមានតំណាងក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច សាលារាជធានីភ្នំពេញ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ កងរាជអាវុធហត្ថផ្ទៃប្រទេស អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី, UN-ACT, LSWC, Cambodia ACTs, IJM, APLE, Chab Dai និង Winrock In't ។

គោលបំណងនៃកិច្ចប្រជុំគឺ រាយការណ៍អំពីផែនការអនុវត្ត តួនាទី ភារកិច្ច ការទទួលខុសត្រូវ និងវឌ្ឍនៈភាពការងាររបស់ក្រុមនីមួយៗ ព្រមទាំងពិភាក្សាលើការងារពាក់ព័ន្ធក្នុងការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦។

**បន្ទាប់ពីបានប្រជុំពិភាក្សាចូលរួមយោបល់ពីគ្រប់ស្ថាប័ន-អង្គភាពរួចមក អង្គប្រជុំទទួលបានលទ្ធផលដូចខាងក្រោម ៖**

ក. វឌ្ឍនៈភាពការងារ

- ការងារដែលបានត្រៀមរួច
  - បានត្រៀមរួចរាល់នូវគំរូមួយចំនួនដូចជា៖ កម្មវិធី ឡូហ្គោ អាវ ថង់ពត៌មាន លិខិតអញ្ជើញ សៀវភៅ ។
  - សារ និងពាក្យស្លោក បានបញ្ជូនទៅកាន់សាលារាជធានីភ្នំពេញដើម្បីផលិតជាបដា ។
  - ក្រុមសន្តិសុខ៖ ផ្លាកសម្គាល់ និងប័ណ្ណចេញចូល គ.ជ.ប.ជជាអ្នកផលិត រួចបញ្ជូនទៅប្រថាប់ត្រានៅនាយកដ្ឋានអង្គរក្ស ។
  - ក្រសួងព័ត៌មានត្រៀមរួចជាស្រេចសម្រាប់ការចាក់ផ្សាយ និងផ្សព្វផ្សាយ។
  - ក្រសួងវប្បធម៌កំពុងដំណើរការរៀបចំការសម្តែងសិល្បៈ ។
  - បទយការណ៍បានផលិតរួចហើយ (តែមិនទាន់បានកាត់តសម្រេច) មានរយៈពេលប្រហែល ៣០នាទី ដែលគោលបំណងនៃបទយកការណ៍នេះ បង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងកិច្ចសហការជា មួយអង្គការនានា ក្នុងការកាត់បន្ថយអំពើជួញដូរមនុស្ស ។ ក្នុងបទយកការណ៍នេះក៏បានបញ្ចូលនូវអនុសាសន៍ និងវិធានការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី និងសម្តេចឧបនាយករដ្ឋមន្ត្រី ដែលបានលើកឡើងកាលពីទិវា១២ធ្នូ ឆ្នាំមុនផងដែរ ។ នាយកដ្ឋានផ្សព្វផ្សាយអប់រំក៏បានស្នើសុំ ឲ្យជួយផ្តល់រូបភាពពាក់ព័ន្ធនឹងការបញ្ជូនជនរងគ្រោះពីបរទេស តាមជើងអាកាស ព្រោះមិនទាន់មាន ។

▪ ការអញ្ជើញភ្ញៀវចូលរួម

- សាលារាជធានី អញ្ជើញអ្នកដែលឋិតនៅក្រោមសាលារាជធានី ប្រជាពលរដ្ឋ មន្ត្រីស៊ីវិល នគរបាល អាវុធហត្ថ ក្រុមកាយរិទ្ធ យុវជនកាកបាទក្រហម សហព័ន្ធយុវជន និងសិស្សានុសិស្ស ។
- ក្រសួងអប់រំ អញ្ជើញខាងសាកលវិទ្យាល័យ ។
- អញ្ជើញកងរាជអាវុធហត្ថផ្ទៃប្រទេស កងទ័ពជើងគោក ទឹក និងអាកាស ត្រូវបញ្ជូនលិខិតអញ្ជើញទៅក្រសួងការពារជាតិ ។
- អញ្ជើញលោកសង្ឃ អាចារ្យ តាជីយាយជី ។
- ក្រុមការងារជាសមាជិកគ.ជ.ប.ជ ត្រូវអញ្ជើញទាំងអស់ ។

▪ ការឧបត្ថម្ភរបស់អង្គការនានា

- Winrock In't ៖ អាវ ៧០០(ចែកតាមខេត្ត) ថង់ព័ត៌មាន ៣៧០០(សម្រាប់ពិធី ៣០០០ និងចែកតាមខេត្ត ៧០០) ប័ណ្ណព័ត៌មាន ៦២០០ ឌីវីឌីវីដេអូ ១៦០ ផ្ទាំងបដា ៥(សៀមរាប ៣ ព្រៃវែង ២)។
- IJM ៖ ផ្លាកសម្គាល់និងខ្សែ ៣០០០ ។
- APLE ៖ មានថវិកាជាង ២០០០ដុល្លា ។
- UN-ACT ៖ រង់ចាំពិភាក្សាសិន ។

ខ. សរុបមតិ និងអនុសាសន៍ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ៖

- ក្រសួង-ស្ថាប័នត្រូវបញ្ជូនបញ្ជីឈ្មោះអ្នកចូលរួមមកឲ្យបានឆាប់ និងត្រូវធ្វើការតាមដានផងដែរ ។
- ខាងអង្គការត្រូវបញ្ជូនចំនួនអ្នកចូលរួមមកឲ្យបានឆាប់ ។
- ចំពោះកងកម្លាំងនឹងចែកអាវទុកជាអនុស្សាវរីយ៍ តែពេលចូលពិធីត្រូវពាក់ឯកសណ្ឋានតាមផែន ។
- សុំឲ្យក្រសួង-ស្ថាប័ន អង្គភាព អង្គការដែលមានមុខសញ្ញា ជួយក្នុងក្នុងការបញ្ជូនលិខិតអញ្ជើញ ។
- សុំឲ្យក្រុមនីមួយៗជួបប្រជុំគ្នា ដើម្បីសម្រេចការងារឲ្យបានឆាប់ ។
- សុំឲ្យក្រុមនីមួយៗលើកគម្រោងថវិកាមកឲ្យបានឆាប់ ។
- សុំឲ្យមានលទ្ធផលយ៉ាងយូ១សប្តាហ៍ទៀត ។

ជូ-ប៊ុនអេង

01/12/2016

កិច្ចប្រជុំបានប្រព្រឹត្តទៅយ៉ាងផុលផុស និងបានបញ្ចប់នៅវេលាម៉ោងដប់មួយថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០១៦

**អ្នកកត់ត្រា**

ធុំ.ចរិយា

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦

**ប្រធានលេខាធិការដ្ឋាន**

## សមាសភាពចូលរួមកិច្ចប្រជុំ
## រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦
## នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦
## សរុបចំនួន ៤៣ រូប

| | | | |
|---|---|---|---|
| ១ - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ២ - លោកជំទាវ | សាន្ត អរុណ | រដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| ៣ - លោកជំទាវ | សឿ សុជាតា | អនុរដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា |
| ៤ - លោកជំទាវ | ប៊ុន ពុទ្ធី | អនុរដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| ៥ - លោកជំទាវ | សរ គឹមលី | អនុរដ្ឋលេខាធិការ | ក្រសួងព័ត៌មាន |
| ៦ - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| ៧ - ឯកឧត្តម ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៨ - លោកជំទាវ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៩ - លោកជំទាវ | រ៉ែ សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ១០ - ឯកឧត្តម ឧ.ឯក | ជា សារិន | មេបញ្ជាការរង | កងរាជអាវុធហត្ថផ្ទៃប្រទេស |
| ១១ - វរសេនីយ៍ឯក | ពង្ស សារិទ្ធ | បញ្ជាការរង នាយសេនាធិការ | កងរាជអាវុធហត្ថរាជធានីភ្នំពេញ |
| ១២ - ឯកឧត្តម | ឯក ប៊ុនថៅ | អគ្គនាយករង | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ១៣ - លោកជំទាវ | ម៉ក់ វណ្ណស៊ីថា | អភិបាលរងរាជធានី | សាលារាជធានីភ្នំពេញ |
| ១៤ - លោក | លឹម ណូរ៉ា | រដ្ឋបាល | សាលារាជធានីភ្នំពេញ |
| ១៥ - លោក | កង់ សុភ័ក្រ្ត | មន្រ្តីពិធីការ | សាលារាជធានីភ្នំពេញ |
| ១៦ - លោក | ផយ ពណ្ណ | អនុប្រធានការិយាល័យ | សាលារាជធានីភ្នំពេញ |
| ១៧ - ឧត្តមសេនីយ៍ត្រី | ហេង ចាន់ធារី | ស្នងការរង | ស្នងការដ្ឋានរាជធានីភ្នំពេញ |
| ១៨ - លោកស្រី ឧ.ទោ | ម៉ន វិមាន | អនុប្រធាននាយកដ្ឋាន | អគ្គលេខាធិការដ្ឋាន |
| ១៩ - លោក | សេ រ៉ាឌី | អនុប្រធានការិយាល័យពិធីការ | អគ្គលេខាធិការដ្ឋាន |
| ២០ - ឧត្តមសេនីយ៍ត្រី | នួន ច័ន្ទថុល | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានអង្គរក្ស |
| ២១ - លោកស្រីឧ.ត្រី | ជ័យ បុប្ផា | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានសុខាភិបាល |
| ២២ - វរសេនីយ៍ឯក | សំ យ៉ន | នាយការិយាល័យ | នាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| ២៣ - លោក | សេក មុនី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ២៤ - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ២៥ - លោក | តិប សុផល | អនុប្រធានការិយាល័យ | ក្រសួងអប់រំ យុវជន និងកីឡា |
| ២៦ - ឧត្តមសេនីយ៍ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានស្តីទី | គ.ជ.ប.ជ |
| ២៧ - ឧត្តមសេនីយ៍ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ២៨ - ឧត្តមសេនីយ៍ត្រី | ស្រី សាមឌី | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ២៩ - វរសេនីយ៍ឯក | កែវ សុវណ្ណារ៉ា | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៣០ - លោក | តែ សុថារ៉េត | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៣១ - លោក | ឆេង វណ្ណា | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ៣២ - វរៈសេនីយ៍ត្រី | អ៊ិន មាន | ជំនួយការអនុប្រធានអចិន្ត្រៃយ៍ | គ.ជ.ប.ជ |
| ៣៣ - អនុសេនីយ៍ឯក | ហ៊ី រតនៈ | អនុប្រធានការិយាល័យ | គ.ជ.ប.ជ |

| | | | |
|---|---|---|---|
| ៣៤ - លោកស្រី | អ៊ីសស្ទើរ ពិសីយ៉េម | មន្ត្រីគម្រោង | ជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី |
| ៣៥ - លោក | អៀង ប៊ុនថន | មន្ត្រីគម្រោង | UN-ACT |
| ៣៦ - លោកស្រី | ប៊ុន លីនដា | មន្ត្រីគម្រោង | LSWC |
| ៣៧ - លោក | គង់ វីឡា | អគ្គលេខាធិការ | Cambodia ACTs |
| ៣៨ - លោក | សេក សារឿន | មេធាវី | IJM |
| ៣៩ - លោក | Peter Williams | Director | IJM |
| ៤០ - លោក | Neng Vannak | Comms Officer | APLE |
| ៤១ - លោកស្រី | Aisha Faruqi | Lawyer | Chab Dai |
| ៤២ - លោកស្រី | Savun Puthik | Project Coordinator | Chab Dai |
| ៤៣ - លោក | សុខ សុគន្ធា | អ្នកគ្រប់គ្រងផ្នែកទំនាក់ទំនង | Winrock In't |